01318688

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 16 / 08 / 2016
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

E319/52/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៦

**ជូនចំពោះ÷** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី÷** ចៅក្រម យ៉ា សុខន ជ.ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ÷** សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ស្នើសុំពន្យារពេលឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ E319/52

១. នៅថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយរបស់មេធាវីការពារក្តី ខៀវ សំផន ("សំណើ" ឯកសារ E319/52/1) សុំពន្យារពេលឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលសុំឱ្យអង្គជំនុំជម្រះទទួលយកឯកសារចំនួន ៣៥ ពីសំណុំរឿង ០០៤ ធ្វើជាឯកសារភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ អនុលោមតាមវិធាន ៨៧(៣) និង (៤) នៃវិធានផ្ទៃក្នុង (ឯកសារ E319/52)។

២. មេធាវីការពារក្តី ខៀវ សំផន លើកឡើងថា ទោះបីជាឯកសារ E319/52 ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៦ ត្រូវបានជូនដំណឹងដល់ភាគីនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ ក៏ដោយ តែភាគីទើបតែអាចចូលពិនិត្យមើលឯកសារដែលស្នើសុំទាំងនោះបាននៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦ ប៉ុណ្ណោះ។ មេធាវីការពារក្តីលើកឡើងបន្ថែមថា រយៈពេល ១០ ថ្ងៃ ដែលកំណត់ដោយច្បាប់សម្រាប់ដាក់ចម្លើយតប ផ្តល់ពេលវេលាមិនគ្រប់គ្រាន់ក្នុងការពិនិត្យមើលឯកសារ

ថ្មីចំនួន ៣៥ ទេ ជាពិសេស ដោយពិចារណាដល់បន្ទុកការងារនាពេលបច្ចុប្បន្នរបស់មេធាវីការពារក្ដី (ឯកសារ E319/52/1 កថាខណ្ឌ ៤-៧)។ មេធាវីការពារក្ដី ខៀវ សំផន បានស្នើសុំពន្យារពេល ៣០ ថ្ងៃ ដើម្បីដាក់ចម្លើយតបរបស់ខ្លួន រហូតដល់ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ (ឯកសារ E319/52/1 កថាខណ្ឌ ៨, ១២)។

៣. បន្ទាប់ពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់ភាគី ក្នុងអំឡុងពេលកិច្ចប្រជុំរៀបចំសវនាការ ដែលបានធ្វើនៅថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងសម្រេចអនុញ្ញាតតាមសំណើសុំ។ ហេតុនេះ ភាគីត្រូវដាក់ចម្លើយតបរបស់ខ្លួនទៅនឹងឯកសារ E319/52 ត្រឹមថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦។ អង្គជំនុំជម្រះសាលាដំបូងនឹងសម្រេចទៅលើផ្នែកផ្សេងទៀតនៃសំណើសុំក្នុងពេលសមស្របខាងមុខ។